# សារជាតិមមាច

(បទកាកគតិ)

មមាចឃើញភ្លើង មមីងមមើង ភាន់ភាំងចិន្តា
អគ្គីក្រហម នឹកស្មានបុប្ផា ហោះហើរឆ្វេឆ្វា
ផ្វែលឆាបប្រលែង។

ភ្លូកភ្លឹកភ្លើតភ្លើន ប្រហែសព្រហើន ឫកពាខែងវែង
វង្វេងវិវក់ នឹងភ្នក់ភ្លើងផ្សេង នឹកថាខ្លួនឯង
ក្រៃលែងហ៊ឺហា។

ត្រូវភ្លើងសែនក្តៅ ឆេះកាយខ្មុកខ្មៅ ដល់ក្តីមរណា
ព្រោះមិនគិតដល់ ក្រហល់ចិន្តា ឃើញភ្លើងថាផ្កា
អនិច្ចាខុសអស់។

សត្វមមាចអើយ! បានឃើញអ្នកហើយ សង្វេគស្រណោះ
អ្វីហ្ន៎! បណ្តាល អោយជាដូច្នោះ ទើបបានខំហោះ
បោះកាយចូលភ្លើង។

ឬព្រោះសន្តាន អ្នកជាតិរច្ឆាន សារជាតិមិនថ្កើង
ខ្វះធម្មសញ្ញា ទើបហ៊ានចចើង អោយចិត្តជោរឡើង
តាមនិស្ស័យសត្វ។

មិនខុសមនុស្សមិញ ខ្លះគ្មានទោម្នេញ គិតតែច្រវាត់
សប្បាយនឹងលួច ឆបោកបំបាត់ ឆក់ប្លន់វាយស្កាត់
គំរាមទាមទារ។

សាងកម្មអប្រិយ អោយជនប្រុសស្រី ភ័យខ្លាចគ្រប់គ្នា
ថ្ងៃបង្កឈ្លោះ អោយមោះនាមា យប់ដើររវោ
ត្រាច់ស្វែងរកលាភ។

អ្នកផងស្អប់ខ្លាច ឯងធ្វើអង់អាច សាងអស្ថេរភាព
សុខលើទុក្ខគេ ខូចខុសរបៀប កាយមនុស្សចិត្តទាប
ប្រៀបដូចតិរច្ឆាន។

លង់កម្មអាក្រក់ អោយកករល្អក់ ឫកបែបថ្លើងថ្កាន
នឹកថាគេកោត ចិត្តឆោតក្លាហាន តាមពិតស្អុយប្រាណ
អសោចិ៍អស់កេរ្តិ៍។

ដល់ថ្ងៃអស់លក្ខណ៍ គង់បានដឹងជាក់ ថាខ្លួនខុសគេ
ជាជនឫស្យា ស្អុយឈ្មោះទទេ មានគុកជាគេហ៍
ខ្មោះឃ្មោងកំដរ។

ណ្ហើយចុះ! មិនថ្វី បើជ្រុលអប្រិយ ឆាប់កែលំអ
ឈប់សាងបាបកម្ម ខំសាងក្តីល្អ ជាមនុស្សបវរ
ស្គាល់គុណទោសា។

អំពើសាមាន្យ ទុកអោយតិរច្ឆាន វាធ្វើចុះណ៎ា
ព្រោះវាជាសត្វ ពុំចេះវិចារណ៍ យើងជាមនុស្សា
មានចិត្តថ្លៃថ្នូរ។

រឿងអាក្រក់ល្អ ខ្មៅហើយនិងស យើងស្គាល់ហែហូរ
កាន់ឫកជាមនុស្ស កុំចង់ដោះដូរ គង់ផុតថ្ងូចថ្ងូរ
សុខតរៀងទៅ។✍

(២៥ មករា ២០០២)

ភិក្ខុ ស្វាត សាលឿម